**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០១៦/១១/២០០៨ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៨

# ជម្រាបមក

**លោក សុខ សុភក្តិ** តំណាងគណបក្ស សម រង្ស៊ី

ប្រធានការិយាល័យនីតិកម្មគណបក្ស សម រង្ស៊ី រាជធានីភ្នំពេញ

**កម្មវត្ថុ** : រឿងទាក់ទងនឹងបណ្តឹងរបស់លោក សុខ សុភក្តិ ប្តឹងបដិសេធលទ្ធផលនៃការបោះឆ្នោតសង្កាត់បឹងសាឡាង និងសុំឱ្យមានការរៀបចំការបោះឆ្នោតឡើងវិញ

**យោង** : បណ្តឹងគ្មានលេខ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៨ របស់លោក សុខ សុភក្តិ តំណាងគណបក្ស សម រង្ស៊ី

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបមក លោក សុខ សុភក្តិ ជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើបណ្តឹងរបស់លោករួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកបណ្តឹងនេះមកពិភាក្សា និង សម្រេចបានឡើយ ពីព្រោះបណ្តឹងរបស់លោកមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ២៥ថ្មី មាត្រា ២៦ និងមាត្រា ២៧ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង មាត្រា ៧៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**